**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ១៩៥ **ក.ប**/ប្រ.ក

# ប្រកាស
# ស្តីពី
# ប័ណ្ណការងារ និងសៀវភៅការងារ ជនបរទេស

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម/០៣៩៧/០០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នសរកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសរួមលេខ ១០០៩ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញលិខិតលេខ ៣៧៨ សជណ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សម្រេច

**ប្រការ១.-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ដែលត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេស ឬជនបរទេសដែលចូលមក ប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទស្នើសុំប័ណ្ណការងារ និងសៀវភៅការងារឱ្យបានត្រឹមត្រូវ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រភេទ២.-**

ចំពោះជនបរទេសមានទិដ្ឋាការស្នាក់នៅមានរយៈពេលកំណត់

ក.សំណុំបែបបទសម្រាប់ស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេស រួមមាន៖

១-ពាក្យស្នើសុំប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រ៍ ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន ៤សន្លឹក។

២-សេចក្តីបញ្ជាក់របស់ម្ចាស់សហគ្រាស គ្រឹះស្ថាន អំពីចំនួនកម្មករនិយោជិតខ្មែរ និងចំនួនជនបរទេសដែលមានបច្ចុប្បន្ន ចំនួន០១ច្បាប់។

៣-សេចក្តីថតចម្លងលិខិតឆ្លងដែនជនបរទេសម្នាក់ៗ ចំនួន០១ច្បាប់។

៤-អាករប្រចាំឆ្នាំ និងកម្រៃសេវាដែលជនបរទេសម្នាក់ៗត្រូវបង់ចំនួន ៤០០ ០០០ (បួនរយពាន់) រៀល។

៥-កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេស ចំនួន ០១ច្បាប់។

៦-វិញ្ញាបនបត្របញ្ជាក់ថា មានកាយសម្បទាសមស្របនឹងមុខរបរ ដែលចេញឱ្យដោយស្ថាប័ន មានសមត្ថកិច្ចរបស់ប្រទេសដើម ដែលមានសុពលភាពមិនលើសពី៦ខែ ចំនួន០១ច្បាប់។

ចំពោះជនបរទេសដែលចូលមកដល់ព្រះរាជាណាចក្រកម្ពុជារួចហើយ តែមិនទាន់មានវិញ្ញាបនបត្រនេះ ត្រូវមានវិញ្ញាបនបត្របញ្ជាក់កាយសម្បទា ដែលមានសេចក្តីសន្និដ្ឋានថា អាចធ្វើការបាន ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន០១ច្បាប់។

ខ.សំណុំបែបបទសម្រាប់ស្នើសុំពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងាររួមមាន៖

១-ពាក្យស្នើសុំពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រ៍ ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន០១សន្លឹក។

២-សេចក្តីបញ្ជាក់របស់ម្ចាស់សហគ្រាស គ្រឹះស្ថាន អំពីចំនួនកម្មករនិយោជិតខ្មែរ និងចំនួនជនបរទេសដែលមានបច្ចុប្បន្ន ចំនួន០១ច្បាប់។

៣-សេចក្តីថតចម្លងលិខិតឆ្លងដែនជនបរទេសម្នាក់ៗ ចំនួន០១ច្បាប់។

៤-អាករប្រចាំឆ្នាំ និងកម្រៃសេវាដែលជនបរទេសម្នាក់ៗត្រូវបង់ចំនួន ៤០០ ០០០ (បួនរយពាន់) រៀល។

៥-កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេស ចំនួន០១ច្បាប់។

៦-វិញ្ញាបនបត្របញ្ជាក់ថា មានកាយសម្បទាដែលមានសេចក្តីសន្និដ្ឋានថា អាចធ្វើការបានដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន០១ច្បាប់។

**ប្រការ៣.-**

ចំពោះជនបរទេសដែលចូលមកធ្វើការនៅតំបន់ត្រីកោណ កម្ពុជា វៀតណាម ឡាវ (បានតែជនបរទេសដែលមានសញ្ជាតិវៀតណាម និងឡាវ ហើយដែលរស់នៅជាប់ព្រំប្រទល់ខេត្តចំនួន៤ របស់ព្រះរាជាណាចក្រកម្ពុជា គឺខេត្តស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី និងរតនគិរី)។

**ក.សំណុំបែបបទសម្រាប់ស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេសៈ**

១-ពាក្យស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រ៊ី ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន៤សន្លឹក។

២-សេចក្តីបញ្ជាក់របស់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អំពីចំនួនកម្មករនិយោជិតខ្មែរ និងចំនួនកម្មករនិយោជិតបរទេស ដែលមានបច្ចុប្បន្ន ចំនួន០១ច្បាប់។

៣-សេចក្តីថតចម្លងលិខិតឆ្លងដែនជនបរទេស ឬប័ណ្ណឆ្លងព្រំដែន (Border Pass) ឬប័ណ្ណបើកផ្លូវ (Laissez-passer) ឬលិខិតដែលភាគីទាំងពីរបានឯកភាពគ្នា ចំនួន ០១ច្បាប់។

៤-អាករប្រចាំឆ្នាំ និងកម្រៃសេវាដែលជនបរទេសម្នាក់ៗត្រូវបង់ចំនួន ៣២០ ០០០ (បីរយម្ភៃពាន់) រៀល។

៥-កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេស ចំនួន ០១ច្បាប់។

៦-វិញ្ញាបនបត្របញ្ជាក់ថា មានកាយសម្បទាសមស្របនឹងមុខរបរ នៅមន្ទីរពេទ្យនៃប្រទេសដើម ឬនៅមន្ទីរពេទ្យក្នុងប្រទេសកម្ពុជា ចំនួន០១ច្បាប់។

**ខ.សំណុំបែបបទសម្រាប់ស្នើសុំពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងារជនបរទេសៈ**

១-ពាក្យស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រ៊ី ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន០១សន្លឹក។

២-សេចក្តីបញ្ជាក់របស់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អំពីចំនួនកម្មករនិយោជិតខ្មែរ និងចំនួនកម្មករនិយោជិតបរទេស ដែលមានបច្ចុប្បន្នចំនួន០១ច្បាប់។

៣-សេចក្តីថតចម្លងលិខិតឆ្លងដែនជនបរទេស ឬប័ណ្ណឆ្លងព្រំដែន (Border Pass) ឬប័ណ្ណបើកផ្លូវ (Laissez-passer) ឬលិខិតដែលភាគីទាំងពីរបានឯកភាពគ្នា ចំនួន ០១ច្បាប់។

៤-អាករប្រចាំឆ្នាំ និងកម្រៃសេវាដែលជនបរទេសម្នាក់ៗត្រូវបង់ ចំនួន ៣២០ ០០០ (បីរយម្ភៃពាន់) រៀល។

៥-កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេស ចំនួន០១ច្បាប់។

៦-វិញ្ញាបនបត្របញ្ជាក់ថា មានកាយសម្បទាសមស្របនឹងមុខរបរ នៅមន្ទីរពេទ្យនៃប្រទេសដើម ឬនៅមន្ទីរពេទ្យក្នុងប្រទេសកម្ពុជា ចំនួន០១ច្បាប់។

**ប្រការ៤.-**

ចំពោះជនបរទេស ដែលត្រូវបានអនុញ្ញាតឱ្យស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់កាតព្វកិច្ចធ្វើប័ណ្ណការងារ និងសៀវភៅការងារ។

ក.សំណុំបែបបទសម្រាប់ស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេសរួមមាន៖

១-ពាក្យស្នើសុំប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រើយ៍ ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន៤សន្លឹក។

២-សេចក្តីបញ្ជាក់របស់ម្ចាស់សហគ្រាស គ្រឹះស្ថាន អំពីចំនួនកម្មករនិយោជិតខ្មែរ និងចំនួនជនបរទេសដែលមានបច្ចុប្បន្ន ចំនួន០១ច្បាប់។

៣-សេចក្តីថតចម្លងលិខិតឆ្លងដែន ឬលិខិតដែលមានតម្លៃស្មើ ដែលក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យស្នាក់នៅអចិន្ត្រៃយ៍ត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន០១ច្បាប់។

៤-អាករប្រចាំឆ្នាំ និងកម្រៃសេវាដែលជនបរទេសម្នាក់ៗត្រូវបង់ចំនួន ២៤០ ០០០ (ពីររយសែសិបពាន់) រៀល។

៥-កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេសចំនួន ០១ច្បាប់។

៦-វិញ្ញាបនបត្របញ្ជាក់ថា មានកាយសម្បទាសមស្របនឹងមុខរបរ ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសដើម ដែលមានសុពលភាពមិនលើសពី ៦ខែ ចំនួន០១ច្បាប់។

ចំពោះជនបរទេសដែលចូលមកដល់ព្រះរាជាណាចក្រកម្ពុជារួចហើយ តែមិនទាន់មានវិញ្ញាបនបត្រនេះ ត្រូវមានវិញ្ញាបនបត្របញ្ជាក់កាយសម្បទា ដែលមានសេចក្តីសន្និដ្ឋានថាអាចធ្វើការបាន ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន០១ច្បាប់។

**ខ.សំណុំបែបបទសម្រាប់ស្នើសុំពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងាររួមមាន៖**

១-ពាក្យស្នើសុំប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រើយ៍ ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន៤សន្លឹក។

២-សេចក្តីបញ្ជាក់របស់ម្ចាស់សហគ្រាស គ្រឹះស្ថាន អំពីចំនួនកម្មករនិយោជិតខ្មែរ និងចំនួនជនបរទេសដែលមានបច្ចុប្បន្ន ចំនួន០១ច្បាប់។

៣-សេចក្តីថតចម្លងលិខិតឆ្លងដែន ឬលិខិតដែលមានតម្លៃស្មើ ដែលក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យស្នាក់នៅអចិន្ត្រៃយ៍ត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន០១ច្បាប់។

៤-អាករប្រចាំឆ្នាំ និងកម្រៃសេវាដែលជនបរទេសម្នាក់ៗត្រូវបង់ចំនួន ២៤០ ០០០ (ពីររយសែសិបពាន់) រៀល។

៥-កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេសចំនួន ០១ច្បាប់។

៦-វិញ្ញាបនបត្របញ្ជាក់កាយសម្បទា ដែលមានសេចក្តីសន្និដ្ឋានថាអាចធ្វើការបាន ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន០១ច្បាប់។

**ប្រការ៥.-**

ការបង់អាករពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងារ ត្រូវធ្វើឱ្យហើយមុនដំណាច់ខែ មីនា នៃឆ្នាំនីមួយៗ។ ក្នុងករណីដែលរកឃើញមានការខកខានមិនបានពន្យារសុពលភាពទៅតាមការកំណត់ខាងលើនេះទេ សហគ្រាស គ្រឹះស្ថាន ដែលប្រើសាមីជនបរទេសត្រូវចាត់ទុកថា បានរក្សាទុក ឬប្រើប្រាស់ជនបរទេស ដោយមិនមានប័ណ្ណការងារ និងសៀវភៅការងារ។

**ប្រការ៦.-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយ នៃប្រកាសនេះនឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូក១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៨
  "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ